# សូមជូនៈ រឿងកំប្លែងខ្លីៗ




រៀបចំដោយៈ

**UM ERO**

Neak Paon Organization for Development

Kampong Cham Province


៚៚៚ ❀ ៙៙៙

## ទឹកនោមផ្អែម

ថ្ងៃមួយមានតាចាស់ម្នាក់គាត់មានជំងឺទឹកនោមផ្អែម ប៉ុន្តែគាត់ពុំដឹងថាគាត់មានជំងឺនេះទេ ហើយបានទៅពិនិត្យ។ នៅពេល លោកគ្រូពេទ្យប្រាប់គាត់ថា លោកតាមានជំងឺទឹកនោមផ្អែម ពេលនោះលោកគ្រូពេទ្យអោយគាត់សំរាកព្យាបាលជំងឺនៅមន្ទីរពេទ្យ១អាទិត្យ។ លោកគ្រូពេទ្យ បានប្រាប់លោកតាថា ប្រសិនបើលោកតាឈឺជុះនោម លោកតាមិនបាច់ទៅបង្គន់ទេ លោកតានោមដាក់ដប ហើយទុកដាក់នៅជិតទូចានចុះ។ លោកតាក៏ធ្វើតាមបញ្ជាលោកគ្រូពេទ្យ។ នៅពេលលោកតាសំរាន្ត លោកគ្រូពេទ្យ ពីរ-បីនាក់ដើរមករកអ្វីហូប។ គាត់ឃ្លានខ្លាំងណាស់ ពេលនោះក៏បើកទូចាន ឃើញដបទឹកនោមស្មានថាជាដបទឹកត្រី ពេលគាត់ភ្លក់ហើយគាត់និយាយថា បានទឹកត្រីផ្អែមហើយម្តេចបានជាមិនប្រាប់អញផង ខំតែដើររកអ្វីស៊ីពុំបានផង ពេលនោះគាត់ក៏ហូបបាយជាមួយយទឹកនោមផ្អែម។ បន្ទាប់មកលោកតាលឺក៏ភ្ញាក់ឡើង ឃើញពេទ្យ ពីរ- បីនាក់កំពុងហូបបាយជាមួយទឹកនោមផ្អែម គាត់និយាយថាឃើមានចោរកំពុងលួចទឹកនោមអញផង អញទុកទឹកនោមផ្អែមអោយគេពិនិត្យទេវើយ!!!

# ទឹកដោះម៉ែ

មានគ្រួសារមួយមានកូនពីរនាក់ កូនប្អូនអាយុ ២ ឆ្នាំ កូនបងអាយុ ៤ ឆ្នាំ ។ ពួកគេឈ្លោះប្រកែកគ្នាពីរឿងបោះដោះម្តាយ។ កូនបងនិយាយថា យើងនឹងដាក់ថ្នាំបំពុលនៅលើក្បាលដោះម៉ែ អោយឯងស្លាប់តែម្តង។ កូនបងក៏បានធ្វើដូចដែលខ្លួនបានគិត។ ស្រាប់តែ ព្រឹកឡើង ឃើញឪពុក ស្លាប់ទៅវិញ។ តើអ្នកយល់ថាមានរឿងអ្វីកើតឡើង???

# ទូរស័ព្ទច្រលំលេខ

នៅពេលយើងនិយាយទូរស័ព្ទយើងប្រើពាក្យ អាឡូ-អាឡូ។ ស្រាប់តែបុរសម្នាក់និយាយទូរស័ព្ទទៅកាន់ជនជាតិចាមម្នាក់ ហើយជនជាតិចាមនោះក៏លើកទូរស័ពទទួលលឺសូរពាក្យថា អាឡូ-អាឡូ ហើយក៏ធ្វើការឆ្លើយតបវិញថាៈ លោកច្រលំលេខទូរស័ព្ទហើយ ឡិនមិនមែនឈ្មោះអាឡូទេ លិនឈ្មោះអាលាស់។ សូមទោសលោកច្រលំលេខហើយ។

# ជ្រូកខ្វៃកំពប់ទឹកជ្រលក់

មុនថ្ងៃចូលឆ្នាំចិន មានប្តីប្រពន្ធពីរនាក់បានទិញជ្រូកខ្វៃមួយក្បាល ហើយខ្លាចចោរលួចក៏ដាក់អន្ទាក់។ បន្ទាប់មកមានចោរពីរក្រុម ក្រុមស្រី និងក្រុមប្រុស ខាងក្រុមស្រីដឹងថាមានអន្ទាក់ ខាងប្រុសមិនដឹងថាមានអន្ទាក់ទេ។ រាត្រីនោះចោរស្រីបានទៅលួចជ្រូក ហើយអោយសមាជិកក្រុមម្នាក់ដោះសំលៀកបំពាក់ចេញអោយអស់ ចងព្យួរធ្វើជាជ្រូកខ្វៃជំនួសថាបន្តិចទៀតនឹងមកជួយ។ ពេលក្រុមស្រីទៅអស់ ក្រុមចោរប្រុសមកលួចម្តង ក៏អោយសមាជិកម្នាក់ទៅស្រាយជ្រូកខ្វៃ។ ចោរម្នាក់ដែលទៅស្រាយនោះ ក៏ប៉ះចំដើមទ្រូងចោរស្រីនោះ ហើយភ័យក៏លេចនោមដាក់ ខោ ហើយមេវានៅខាងក្រៅស្តីអោយថាៈ យី! អានេះគ្រាន់តែអោយស្រាយជ្រូកខ្វៃប៉ុណ្ណឹងក៏អោយកំពប់ទឹកជ្រលក់ដែរ,។



# មនុស្សដែលអត់មានបេះដូង តើស្លាប់ឬរស់?

មានអ្នកគ្រូម្នាក់បង្រៀនជីវវិទ្យានៅវិទ្យាល័យមួយ គាត់មានសង្សារម្នាក់ហើយក៏បានណាត់ជួបគ្នានៅក្រោមដើមពោធិ ។ គាប់ជួនពេលនោះមានសិស្សគេចសាលាពីរនាក់ ជាសិស្សរបស់អ្នកគ្រូផង ម្នាក់ឈ្មោះ ផ្លក់ ។ ម្នាក់ឈ្មោះ ផ្លួយលបតាម ដានការសន្ទនាគ្នារវាងគូស្នេហ៍ទាំងពីរនាក់ ។

*បុរសសង្សារអ្នកគ្រូបានពោលកំណាព្យស្នេហា:*

| | |
|---|---|
| ទឹកជ្រោះហូរជ្រែកកាត់ជ្រលងភ្នំ | ទឹកភ្នែករាមយំកាត់ជ្រលងនាសា |
| រាប់ពាន់តំណក់ស្រក់លើផែនពសុធា | នេះជាសញ្ញាប្រាប់ថា បងនឹក អូនខ្លាំងណាស់ ។ |

*អ្នកគ្រូក៏ពោលពាក្យស្នេហាផ្អែមល្ហែមដែលផុសចេញពីក្រអៅបេះដូងផ្ទាល់តែម្តង:*

| | |
|---|---|
| រូបអូនដូចជាអំពៅ | រូបបងស្រស់ប្រិមប្រិយដូចដំរី |
| ដំរីបើបានរសជាតិផ្អែមហើយ | មិនគួរឃ្លាតឆ្ងាយពីអំពៅទេណាទួនណា ។ |

រូបបងនៅតែស្រលាញ់រូបអូនជានិច្ច លុះអវសាន្តនៃជីវិត ស្នេហារបស់យើងជាស្នេហាគោរពតាម ***ISO 2009*** ក្លិនរបស់អូន ជាក្លិនដ៏ប្រហើរដែលធ្វើអោយបងមិនអាចបំភ្លេចរូបអូនបាន ចាប់ពីពេលនេះតទៅបងគ្មានអ្វីប្រគល់ជូនអូនទេ មានតែបេះដូងបងទេ ដែលនឹងប្រគល់ជូនអូនសំរាប់សាងស្នេហ៍យើងទាំងពីរនាក់ ។

*ស្អែកឡើងអ្នកគ្រូទៅបង្រៀនជីវវិទ្យានៅវិទ្យាល័យ ចំណងជើងមេរៀន:* ***អំពីបេះដូង***

| | |
|---|---|
| អ្នកគ្រូបានសួរ: | ប្អូនណាដឹងមនុស្សយើងអត់បេះដូងស្លាប់ដែរឬទេ? |
| សិស្សពូកែម្នាក់: | បាទអ្នកគ្រូ បើតាមឯកសារជីវវិទ្យាបានអោយដឹងថា មនុស្សយើងអត់បេះដូងគឺស្លាប់ ។ |
| អ្នកគ្រូ: | ប្អូនឆ្លើយបានត្រឹមត្រូវល្អណាស់ ។ |
| ផ្លួយ និង ផ្លក់: | ឈប់ សិន! ឈប់សិន! អ្នកគ្រូ មនុស្សយើងអត់បេះដូងមិនស្លាប់ទេ |
| អ្នកគ្រូ: | ហេតុអ្វីបានជាមិនស្លាប់? |
| ផ្លួយ និង ផ្លក់: | កាលម្សិលមិញ សង្សារអ្នកគ្រូពោលពាក្យស្នេហាផ្អែមល្ហែម ស្នេហាតាម ISO 2009 គាត់ថា ក្លិនអូនប្រហើរ បងប្រគល់បេះដូងអោយអូនចាប់ពីថ្ងៃនេះតទៅហើយ.... ចុះគាត់មានស្លាប់ឯណា ខ្ញុំឃើញគាត់រស់ ងងើម ។ |
| អ្នកគ្រូ: | អុញ! អញ្ចឹងមែន ។ |



# រឿងយក្សរកការងារធ្វើ

កាលពីព្រេងនាយមានយក្សមួយដើររកការងារធ្វើ។ នៅពេលដើររកការងារមិនបាន ក៏ដើរស៊ីមុនស្ស ពីភូមិមួយទៅភូមិមួយទៀត។ ថ្ងៃមួយយក្សដើរស៊ីមនុស្សក៏ជួបអ៊ីម្នាក់ ពេលនោះយក្សអោនខ្លួនចង់ស៊ីអ៊ីនោះ ពេលនោះអ៊ីនោះខ្លាចក៏និយាយថាៈ លោកយក្សខ្ញុំលឺសួរលោកយក្សដើររកការងារធ្វើមែនទេ.? យក្សតប ពិតមែនហើយ។ នៅពេលនោះ អ៊ីនោះក៏ដករោមមួយសរសៃអោយទៅយក្ស ហើយនិយាយថាៈ លោកយក្សយករោមនេះអ៊ុតអោយត្រង់។ ពេលនោះអ៊ីក៏រួចខ្លួនពីសេចក្ដីស្លាប់។ យក្សយករោមទៅអ៊ុត៣រឺ៤ ខែ នៅតែមិនត្រង់ក៏ខឹងចិត្ត ក៏ទៅរកអ៊ីម្នាក់នោះវិញ។ នៅពេលទៅរក អ៊ីនោះកំពុងតែងូតទឹក លឺថាយក្សមក ក៏បើកវាំងននងូតទឹកចេញ ហើយយក្សឃើញក៏លាន់មាត់ថាៈ ងាប់ហើយមួយសរសៃអ៊ុត ៤ ខែមិនត្រង់ ចុះទំរាំមួយក្រញ៉ុម!!!

# សូមផ្ដាំទៅចៅផង

សម័យថ្ងៃមួយ មានតាចាស់ម្នាក់ទៅលេងចៅគាត់នៅទីក្រុងភ្នំពេញ គាត់បានជិះរថយន្តក្រុង ហើយគាត់បានឈប់នៅបេនឡានស្ទូរិយា។ គាត់បានចុះពីរលើរថយន្តក្រុង ហើយបានដើរសំដៅទៅ តេទូរសព្ទសាធារណៈ។ តានិយាយថាៈ អាឡូ! អាឡូ! ក្រុមហ៊ុនទូរស័ព្ទបានឆ្លើយតបថា មិនមានការឆ្លើយតបទេ។ លោកតាក៏ឆ្លើយថា មិនអីទេមិនមានការឆ្លើយតបក៏ហីចុះ ប៉ុន្តែតាសូមផ្ដាំទៅចៅតាអោយមកទទួលតានៅបេនឡានស្ទូរិយាផង។

# រឿងអាឡូ

មានមីងម្នាក់នៅខេត្តព្រៃវែងមានកូនឈ្មោះអាឡូ ស្រាប់មានទូរស័ព្ទ Call មក ដោយនិយាយថា អាឡូ! អាឡូ! មីងនោះមិនដឹង ក៏ឆ្លើយថា អាឡូកូនខ្ញុំ វាទៅភ្នំពេញហើយ។

# ប៉ូលីសផាកពិន័យ

មានអ្នកស្រែពីរនាក់មកលេងទីក្រុងភ្នំពេញ ហើយអ្នកទាំងពីរមិនដែលឃើញផ្ទះថ្មក៏សំលឹងមើលផ្ទះថ្ម ១០ ជាន់ បន្ទាប់មកប៉ូលីសផាកពិន័យ មីងមើលអ្វីហ្នឹង? មីងនោះឆ្លើយថា មើលផ្ទះថ្ម ។ តើមីងមើលអស់ប៉ុន្មានជាន់អំបាញ់មិញ? មីងឆ្លើយថា មើលអស់៣ ជាន់។ តើ១ ជាន់លោកប៉ូលីសផាកពិន័យប៉ុន្មានបើតាមច្បាប់ចរាចរណ៏? ១ ជាន់ត្រូវផាកពិន័យ ១០០០ រៀល ដូច្នេះ ៣ ជាន់ត្រូវផាកពិន័យ ៣០០០ រៀល។ មីងក៏អោយលុយទៅប៉ូលីស ហើយនៅដែលដើរផុតពីប៉ូលីស បានបន្ដិចមីងនោះ បាននិយាយប្រាប់មិត្តភ័ក្ដគាត់ថា នែពួកម៉ាក អញមើលផ្ទះថ្មដល់១០ជាន់ឯនោះ អញភរថា៣ជាន់ជឿអញដែរអាប៉ូលីសនេះ ចំជាភ្លើមែន!!!

# សត្វមូស

កាលពីអតីតកាល មូសនៅស្រុកស្រែមានមិត្តភក្ដិនៅទីក្រុង។ មូសនៅទីក្រុងបាន តេតាមទូរស័ព្ទមកមូសនៅស្រុកស្រែ។ មូសទីក្រុង: អាឡូមិត្តភក្ដិនៅស្រុកស្រែសំបូរអ្វីទេ? មូសស្រុកស្រែឆ្លើយថា សំបូរណាស់សំលាញ់ មានទាំងគោធាត់ទៀតផងបេញបេញទៅដោយឈាម។ មូសនៅទីក្រុងមិនសូវសំបូរអ្វីស៊ីទេ ដោយសារនាពេលរាត្រីមនុស្សម្នាក់ៗដេកយប់សុទ្ធតែចងមុងគ្រប់គ្នាៗ។ មូសទីក្រុងបានជិះរថយន្តក្រុងមកលេងមិត្តភក្ដិនៅស្រុកស្រែ។ នាពេលរាត្រី មូសទីក្រុងចេញរកចំនី ហើយបានខាំគោធាត់ត្រលុកៗមួយក្បាល។ ដោយហេតុតែមូសទីក្រុងមិនដែលបានខាំបឺតឈាមគោ ក៏បានទៅខាំចំស្នែងគោរួចក៏បាក់ធ្មេញអស់រលីង។ បន្ទាប់មកមិត្តភក្ដិសួរ ហេតុអ្វីបានជាយំ អាសំឡាញ់? គ្នាបាក់ធ្មេញអស់រលីងហើយព្រោះខាំចំស្នែងគោ ស្មានថាជាកំប៉ះគូថគោ។ សំលាញ់អើយគ្នាសុំលាទៅទីក្រុងវិញដើម្បីទៅព្យាបាលជំងឺនៅ មន្ទីរពេទ្យកាល់ម៉ែត្រ។



# រឿងផោម

មាននារីស្អាតម្នាក់ទើបនឹងទិញវីវ៉ាថ្មី១គ្រឿង ។ នាងជិះវីវ៉ាបង្អួតគេតាមដងទន្លេមុខវាំង ហើយក៏ជិះបង្ហួសមកដល់ស្ពានជ្រោយចង្វា ។ គាប់ជួននឹងពេលនោះ មានតាចាស់ម្នាក់ ទៅលេងចៅនៅភ្នំពេញ ។ ដោយខ្លាច បាក់ស្ពាន លោកតាក៏ចុះដើរ ។ ស្រាប់តែនាងបើកម៉ូតូភ្លេចមើលលោកតា ក៏រេចង្កូតប៉ះលោកតា ធ្វើអោយគាត់ដួលដាច់ផ្ងារបាស់ជើងច្រងាង ។ លោកតាសួរនាង ថាតើគាត់អាចជួយលើកម៉ូតូអោយទេ នាងនោះក៏ឆ្លើយថា តាឯងមិនបាច់ជួយលើកម៉ូតូខ្ញុំទេ  ខូចម៉ូតូខ្ញុំខូចអស់រលីង ។ នាងក៏លើកម៉ូតូឡើង ហើយនាងលេចផោមលឺសូរ ទិតៗ ទុត ។ លឺដូចនេះ  លោកតានិយាយថា ប្រសិនបើនាងកំប្លែប៉ុណ្ណឹង តាមិនដួលដាច់ផ្ងារទេណាចៅ ។

# ខ្លាចគេឃើញខោលីអ្វូ

មានប្តីប្រពន្ធពីរនាក់ទើបនឹងរៀបការថ្មីៗ  នាំគ្នាដើរលេងតាមមាត់ទន្លេ ។  ប្រពន្ធស្រេកទឹកពេក  ប្តីក៏ដើររកទិញទឹកអំពៅអោយប្រពន្ធ  ដោយទុកចោលប្រពន្ធនៅក្បែរទោងវិល ។  ស្រាប់តែប្រពន្ធនៅមិនស្រណុក  ក៏ឡើងជិះទោងកន្ត្រកវិល ។  នៅមុនពេលជិះទោង  នាងបានយកខោលីអ្វូបត់ដាក់ក្នុងកាបូប ។  ស្រាប់តែប្តីត្រលប់មកវិញ  ឃើញប្រពន្ធជាទីស្រលាញ់របស់ខ្លួន  ឡើងជិះកន្ត្រកវិល ប្តីក៏ស្រែកប្រាប់ប្រពន្ធខ្លួនថា  ប្រយ័ត្នគេឃើញលីអ្វូរបស់អូនឯង ។  ប្រពន្ធតបថា  មិនអីទេបងសំលាញ់ លីអ្វូរបស់អូនដាក់ក្នុងកាបូបបាត់ហើយ  បងមិនបាច់បារម្ភទេ  យ៉ាងហោចណាស់  គេឃើញស្មៅមួយដុំតែប៉ុណ្ណោះណាបងអើយ ។



# ដៃកដុសឆ្នាំង

នាថ្ងៃមួយមានគ្រួសារមួយមានសមាជិក៤នាក់ ។ គ្រួសារនេះមានកូនប្រុសម្នាក់ខូចណាស់ រៀងរាល់ថ្ងៃ គេតែងតែរញ៉េរញ៉ៃអ្នកជិតខាងជានិច្ច ។ ពេលមួយនោះម្ដាយវាធ្វើម្ហូប ហើយគិតថាចាំស្លរួចទៅងូតទឹក ភ្លាមនោះកូនប្រុសរបស់គាត់មកពីដើរលេងវិញ សួរថាម៉ែធ្វើអីហ្នឹង? ម៉ែក៏ឆ្លើយថាម៉ែកំពុងងូតទឹក ។ ម៉ែកូនសុំងូតទឹកជាមួយម៉ែដែរ  ម៉ែក៏យល់ព្រម ។  ម៉ែស្រាតខោអាវអស់រលីង នាពេលនោះកូនឃើញក៏ សួរអ្វីទៅរបស់ខ្មៅមួយក្រញ៉ុមនោះ ម៉ែក៏ឆ្លើយថា ដៃកដុសឆ្នាំងណាកូន ។ កូនក៏សួរបន្តទៀត តើវាថ្លៃប៉ុន្មាន? ម៉ែឆ្លើយថា ៨00 រៀលណាកូន ។ អូខ្ញុំដឹងហើយម៉ែ ។

ពេលក្រោយមកទៀត ប៉ារបស់វាមកពីធ្វើការវិញ ប្រពន្ធអោយប្ដីទៅងូតរួចស៊ីមពិសារបាយ ។ កូនលឺ ដូច្នេះ ក៏ទារងូតទឹកដែរ ។ វាឃើញប៉ាវាងូតទឹកស្រាតខោអាវអស់រលីង ហើយក៏សួរប៉ាវា អ្វីទៅខ្មៅមួយក្រញ៉ុមនោះ? ប៉ាក៏ឆ្លើយថា ដៃកដុសឆ្នាំងណ៎ាកូន ។  កូនក៏សួរបន្តទៀត ថាតើវាថ្លៃប៉ុន្មាន? ប៉ាឆ្លើយថា ៣00 រៀលណ៎ាកូន ។ ដៃកដុសឆ្នាំងប៉ាអ្វីក៏ថោកម្លេះ ដៃកដុសឆ្នាំងរបស់ប៉ាមានដៃកាន់ ចំណែករបស់ម៉ាក់គ្មានដៃកាន់សោះហេតុអ្វីក៏ថ្លៃម្លេះ?

